**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ៣៥៤៦ ព.ណ.ករ.ព..

ថ្ងៃពុធ ១កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្មមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ **ភ្ញៀវជាតិ-អន្តរជាតិ លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជន** ជ្រាបថា ក្រសួងពាណិជ្ជកម្មនឹងរៀបចំ **«ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា» លើកទី១៨** (The 18th Cambodia Trade Expo-CTExpo) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី៤-៧ ខែធ្នូ ឆ្នាំ២០២៥ នៅសាលសន្និបាតភីអេច ហ្រ្វេនហល បុរីប៉េងហួត បឹងស្នោ រាជធានីភ្នំពេញ ក្នុងគោលបំណងលើកកម្ពស់សកម្មភាពពាណិជ្ជកម្មនិងវិនិយោគ និងតួនាទីរបស់វិស័យឯកជន ជំរុញការតភ្ជាប់ទីផ្សារក្នុងស្រុក និងផ្សារភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។

**ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា** ឆ្នាំ២០២៥នេះ នឹងមានរៀបចំការដាក់តាំងបង្ហាញ និងផ្សព្វផ្សាយផលិតផលសក្តានុពលរបស់កម្ពុជាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការនាំចេញ ទំនិញនាំចេញ-នាំចូលដែលមានគុណភាពខ្ពស់ និងសេវាកម្មដែលមានលក្ខណៈពិសេសរបស់បណ្តាអ្នកផ្គត់ផ្គង់កម្ពុជា និងបណ្តាប្រទេសនានា ជាពិសេសមានការរៀបចំស្តង់/បញ្ជរសេវាសាធារណៈនានារបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ ទន្ទឹមនឹងនេះ ក៏នឹងមានរៀបចំកម្មវិធីអមនានាផងដែរ រួមមាន៖ វេទិកាធុរកិច្ច ជំនួបពាណិជ្ជកម្ម សិក្ខាសាលាស្តីពីការជំរុញការនាំចេញ និងការប្រគំតន្ត្រីជាដើម។

ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញ **ភ្ញៀវជាតិ-អន្តរជាតិ លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជន** ដែលមានបំណងចូលរួមតាំងបង្ហាញផលិតផល និងសេវាកម្មក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមអញ្ជើញបំពេញបែបបទស្នើសុំចូលរួមតាមរយៈ QR-Code ខាងក្រោម ឱ្យបានមុនថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៥ ជាកំណត់។

ក្រសួងពាណិជ្ជកម្មមានជំនឿយ៉ាងមុតមាំថា **ភ្ញៀវជាតិ-អន្តរជាតិ លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជន** នឹងអញ្ជើញចូលរួមព្រឹត្តិការណ៍ពិព័រណ៍នេះឱ្យបានកុះករ និងចាប់យកឱកាសដ៏សំខាន់នេះ ក្នុងការពង្រឹង និងពង្រីកសកម្មភាពពាណិជ្ជកម្ម និងវិនិយោគរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍ តាមរយៈទូរស័ព្ទលេខ +៨៥៥ ១៦ ៤១៦ ៨២៥ /+៨៥៥ ៦៩ ៩៤៣ ៨៥៧ ឬតាមរយៈអ៊ីម៉ែល៖ chao.katphuoy@moc.gov.kh៕

**សូមអរគុណ!**

សម្រាប់ចុះឈ្មោះ

GO.gov.KH

ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា
CAMBODIA TRADE EXPO
INTERNATIONAL TRADE EXPOSITION

# «ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា» លើកទី១៨ ឆ្នាំ២០២៥
# THE 18th CAMBODIA TRADE EXPO (CTExpo) 2025

## បែបបទចូលរួមពិព័រណ៍ APPLICATION FORM

កាលបរិច្ឆេទ៖ ថ្ងៃទី៤-៧ ខែធ្នូ ឆ្នាំ២០២៥ — Date : 4-7 December 2025
ទីតាំង៖ សាលសន្និបាត ភីអេច ហ្វេនហល បុរីប៉េងហួតបឹងស្នោ រាជធានីភ្នំពេញ — Venue : PH Convention Center, Borey Peng Huoth Boeng Snor, Phnom Penh
រៀបចំដោយ៖ ក្រសួងពាណិជ្ជកម្ម — Organized by: The Ministry of Commerce

ឈ្មោះក្រុមហ៊ុន(ជាភាសាខ្មែរ)៖ ..........
Company Name(English): ..........

អាសយដ្ឋាន Address ..........
ទូរសព្ទ Tel .......... អ៊ីមែល E-mail ..........

អ្នកទំនាក់ទំនង Contact Person ☐Mr. ☐Ms: .......... | ទូរសព្ទ Tel ..........
តួនាទី Position .......... | អ៊ីមែល Email ..........

| ផលិតផលក្នុងស្រុក Domestic Products | ផលិតផលនាំចូល Import Products |
|---|---|
| ☐ផលិតផលក្នុងស្រុក Domestic Products | ☐ផលិតផលនាំចូល Import Products |
| ☐ផលិតផលនាំចេញ Export Products | ☐នាំចូលពីប្រទេស Import Country.......... |

**ផលិតផលដែលត្រូវយកមកតាំង Exhibit Products (Please ✓)**

| | |
|---|---|
| ☐ផលិតផលកសិកម្ម Agriculture Products | ☐គម្រោងវិនិយោគ Investment Projects |
| ☐ម្ហូបអាហារ និងភេសជ្ជៈ Foods, Beverage | ☐ធនាគារ និងហិរញ្ញវត្ថុ Bank, Finance |
| ☐ផ្លែឈើ បន្លែ Fruit, Vegetable | ☐ត្បូង គ្រឿងអលង្ការ Gems, Jewelry Accessories |
| ☐ទំនិញប្រើប្រាស់ Consumer Goods | ☐សិប្បកម្ម Handicraft |
| ☐ផលិតផលសូត្រ Silk Products | ☐គ្រឿងម៉ាស៊ីន Machinery Equipment |
| ☐គ្រឿងសម្អាង Cosmetics | ☐សម្ភារៈសំណង់ Material Construction |
| ☐ផលិតផលស្ប៉ា Spa Products | ☐គ្រឿងបន្លាស់រថយន្ត Autos Spare-Part |
| ☐សម្លៀកបំពាក់ Garments | ☐គ្រឿងអគ្គិសនី Electrical Appliances |
| ☐វាយនភណ្ឌ Textile | ☐ផ្សេងៗ Other.......... |

**ខ្ញុំសូមចុះឈ្មោះជា I would like to register as:**

☐អ្នកទស្សនា Visitor Only
☐អ្នកតាំងពិព័រណ៍(ស្តង់គំរូ) Exhibitor: Standard Booth (3m x 3m= $9m^2$)
☐អ្នកតាំងពិព័រណ៍(ផ្ទៃទទេ) Exhibitor: Raw Space..........

**គោលបំណង Purpose** ☐លក់ Sale ☐តាំងបង្ហាញ/ផ្សព្វផ្សាយ Display/Advertisement
☐ស្វែងរកដៃគូពាណិជ្ជកម្ម Partnership ☐ផ្សេងៗ Other..........

តំណាងក្រុមហ៊ុន Representative ..........
តួនាទី Position..........
កាលបរិច្ឆេទ Date..........
ហត្ថលេខា Signature ..........
ត្រាក្រុមហ៊ុន Company Stamp